ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.....១៥៨៥.......អពដ

L202203230357 | TD1780

ថ្ងៃពុធ ០៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

# លិខិតអញ្ជើញ

## លោក ផាំង ច័ន្ទតារាឧត្តម នាយកក្រុមហ៊ុន រ៉ា-ថា ឧត្តម

ឈ្មោះក្រុមហ៊ុន ÷ រ៉ា-ថា ឧត្តម
ជាអក្សរឡាតាំង ÷ **RA-THA ODOM CO., LTD**
លេខអត្តសញ្ញាណកម្ម ÷ K010-107031086 ចុះបញ្ជីនៅ ÷ សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ
អាសយដ្ឋាន ÷ #៣៣A-៣៧A ផ្លូវ R-០១ ភូមិ ស្រែជីវៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

---

**កម្មវត្ថុ** ÷ ស្តីពីការអញ្ជើញសហគ្រាសមកទូទាត់បំណុលពន្ធ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជម្រាបជូនលោក ផាំង ច័ន្ទតារាឧត្តម នាយកក្រុមហ៊ុនខាងលើជ្រាបថា ការបង់អាករគឺជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធគ្រប់រូបដើម្បីចូលរួមចំណែកក្នុងថវិកាជាតិ។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានអញ្ជើញលោកនាយកក្រុមហ៊ុនដើម្បីមកដោះស្រាយបំណុលពន្ធរបស់ក្រុមហ៊ុន តាមរយៈលិខិតអញ្ជើញ ជូនដល់អាសយដ្ឋានក្រុមហ៊ុនដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ប៉ុន្តែលោកនាយកមិនបានមកតាមការអញ្ជើញ និងមិនបានទូទាត់បំណុលពន្ធឡើយ។

អនុលោមតាមមាត្រា៩៥ (ថ្មី) ចំណុចទី ៦ កថាខណ្ឌ ខ នៃច្បាប់ស្តីពីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារសូមអញ្ជើញលោកនាយក មកសាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ ទូរស័ព្ទទំនាក់ទំនងលេខ ០១២ ៦១២ ១២០/០១៧ ៩៧៨ ៩៧៩ មិនឲ្យលើសពី១៥ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទលើលិខិតអញ្ជើញក្នុងសារព័ត៌មាននេះ ដើម្បីដោះស្រាយបំណុលពន្ធរដ្ឋ។

ក្នុងករណីលោកនាយក មិនបានអញ្ជើញមកតាមកាលកំណត់ខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនឹងរក្សាសិទ្ធិអនុវត្តតាមផ្លូវច្បាប់ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹមជឿជាក់លើស្មារតីទទួលខុសត្រូវរបស់លោក ផាំង ច័ន្ទតារាឧត្តម នាយកក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។ ៧៥៥

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ចម្លងជូន ÷

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដើម្បីជូនជ្រាប)
- ឯកសារ-កាលប្បវត្តិ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh